# ឋាននរកនិងឋានសួគ៌

ក្នុងសម័យដែលវិទ្យាសាស្ត្រកំពុងតែរីកចំរើនជឿនលឿនទៅមុខយ៉ាងនេះ ផ្នែកសំភារៈចេះតែកើតឡើង ដើម្បីផ្គត់ផ្គង់នូវតម្រូវការរបស់មនុស្ស ។ មនុស្សមួយចំនួនបានឃ្លាតឆ្ងាយពីចរិយាធម៌នៃសភាវៈជាមនុស្ស ព្រោះតែខិតខំដេញតាមសន្ទុះនៃសំភារៈនិយមភ្លេចគិតពីសីលធម៌ និងចរិយាធម៌ដ៏ប្រពៃដែលជាមរតក និងជាអត្តសញ្ញាណរបស់មនុស្ស ។ កាលបើគំនិតលិចលង់វង្វេងវីវក់ឈ្លក់នឹងភោគសម្បត្តិ មុខមាត់ កិត្តិយស មនុស្សក៏ភ្លេចគិតពីតម្រានៃភាពត្រឹមត្រូវ តែគិតថាគំនិតរបស់ខ្លួនឯណេះទេដែលជាគំនិតត្រឹមត្រូវ គំនិតយ៉ាងនេះត្រឹមត្រូវ យ៉ាងនេះថ្លៃថ្នូរ ដោយមិនបានពិចារណាអោយបានហ្មត់ចត់ ។ គេខំសំដែងនូវភាពចេះដឹង របឹងក្រឡាច់ បង្អាច់ពុទ្ធដីកា ដោយពុំបានដឹងពីសភាវៈពិត ខំប្រឹងឱតតែរឿងអាស្រូវដែលជាដង្កូវស៊ីរុករានសព្វសព៌ាង្គកាយនៃកោសិកាសង្គម ។ ហេតុទាំងនេះព្រោះគេមិនបានជឿជាក់ពីបាបបុណ្យគុណទោស ឬឋាននរក ឋានសួគ៌ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសំដែងប្រាប់មក ។ ការមិនជឿនោះមិនមែនមកពីមិនមាននោះទេ តែមកពីមនុស្សទាំងនោះមិនបានប្រើប្រាស់ពេលវេលាស្វែងរកពន្លឺបញ្ញាត្រិះរិះពិចារណាអោយបានដិតដល់ ។ ដើម្បីជាត្រីវស័យក្នុងការពិចារណា សូមលោកអ្នកសប្បុរសទាំងឡាយតាមដានអានអត្ថបទនេះអោយបានចប់ចុងចប់ដើមជាមុនសិន ។

បញ្ហាឋាននរកឋានសួគ៌មានមែនឬក៏អត់នោះ ចាត់ថាជារឿងគួរអោយចាប់អារម្មណ៍ជាទីបំផុត ព្រោះបើយើងពន្យល់អោយបានជាក់ច្បាស់ យើងនឹងបានឈ្មោះថាកាន់សាសនាដោយការពិចារណាយ៉ាងល្អិតល្អន់ ហើយមិនបាច់ធ្វើអោយមានការសង្ស័យជាញឹកញាប់ ចំពោះសាសនាដែលខ្លួនគោរពថាមានហេតុផលដែរទេ ឬ ប៉ុណ្ណា?

*១- ឋានសួគ៌ឋាននរកនៅក្នុងចិត្តរបស់យើងគ្រប់គ្នា ។*

*២- ឋានសួគ៌ឋាននរកនៅក្នុងលោកបច្ចុប្បន្ន ដែលអាចមើលឃើញដោយផ្ទាល់ភ្នែក ។*

*៣- ឋានសួគ៌ឋាននរកដែលមើលមិនឃើញដោយភ្នែក ជារឿងរបស់ភពមួយទៀត ។*

តទៅនេះ នឹងសូមធ្វើអត្ថាធិប្បាយពីបញ្ហាឋានសួគ៌ឋាននរក ដូចដែលបានបែងចែកជា ប្រភេទតាមលំដាប់លំដោយដូចតទៅ:

## ប្រភេទទី១

### ឋានសួគ៌ ឋាននរក នៅក្នុងចិត្តរបស់យើង

ព្រះពុទ្ធសាសនាចាត់ទុកថា ចិត្តរបស់យើងនេះជាផ្នែកសំខាន់បំផុត ក្នុងការបង្គាប់បញ្ជារាង កាយ វាចា អោយធ្វើអ្វីៗបានទាំងផ្លូវល្អទាំងផ្លូវអាក្រក់ ។ កាយរបស់យើងនេះ គ្រាន់តែជា អាយ៉ងសំរាប់អោយចិត្ត

ទាញ ញាក់ លើក ដាក់ សំដែងនូវអាការៈផ្សេងៗ ហើយចិត្តនេះក៏ជា អ្នកដឹង អ្នកទទួលខុសត្រូវជំនួសរាងកាយទាំងអស់ ទោះបីមាននរណាមកជេរស្តីរាងកាយ ចិត្តក៏ជាអ្នកចេញមុខទទួលជំនួសរាងកាយ ។ នៅវេលាដេកលក់ ជាពេលដែលចិត្តសំរាក ទោះបីមាននរណាមកជេរថា ក៏មិនមានអារម្មណ៍ក្រោធខឹង ព្រោះចិត្តមិនដឹង ។ បានសេចក្តីថា រាងកាយដែលប្រាសចាកចិត្តមិនខុសអ្វីពីកំណាត់ឈើ ឬអង្កត់ឧសនោះទេ ។ ដោយសារតែចិត្តជាមេការអ្នកទទួលខុសត្រូវលើទង្វើផ្សេងៗ ដែលខ្លួនបានបង្គាប់បញ្ជាតាមផ្លូវកាយ វាចា ដូច្នេះហើយ ទើបព្រះពុទ្ធសាសនាប្រៀនប្រដៅអោយសិក្សាពីរឿងចិត្តអោយបានហ្មត់ចត់និងជាក់ច្បាស់ជាទីបំផុត ។

ចិត្តដែលពេញទៅដោយអារម្មណ៍ថ្នាក់ទាប គឺជាចិត្តដែលគិតតែពីផ្លូវអាក្រក់ អកុសល ពេលដែលបញ្ជាអោយកាយវាចាសំដែងអាការៈណាមួយចេញមក ក៏រមែងប្រព្រឹត្តទៅតែក្នុងផ្លូវអាក្រក់ ។ ចិត្តប្រភេទនេះ រមែងពោរពេញទៅដោយសេចក្តីក្តៅក្រហាយព្រោះតែអំពើអាក្រក់ខាងក្នុងដុតរោលរាលផង ព្រោះផលនៃអំពើអាក្រក់ដែលបានធ្វើទៅហើយនោះតាមយាយីបៀតបៀនផង ។ មនុស្សទុច្ចរិតកេងប្រវ័ញ្ចអ្នកដទៃ ឬ អ្នកដែលក្រាស់ទៅដោយសេចក្តីក្រោធ សេចក្តីច្រណែនឈ្នានីស រមែងមានចិត្តក្តៅអន្ទះអន្ទែងជានិច្ច បីដូចជាធ្លាក់នរកទាំងរស់ ដែលជាការធ្លាក់នរកតាមផ្លូវចិត្ត ។ ផ្ទុយទៅវិញ បើចិត្តប្រកបដោយគុណធម៌ មានមេត្តាករុណា ចេះជួយជ្រោមជ្រែងស្រោចស្រង់ មានចិត្តត្រេកអរចំពោះជោគជ័យ និងសេចក្តីចំរើនរុងរឿងរបស់អ្នកដទៃ មិនច្រណែនឈ្នានីស ចេះស្អប់ខ្ពើមនូវអំពើអាក្រក់ផ្សេងៗ ចិត្តថ្នាក់ខ្ពស់នេះ ពោរពេញទៅដោយសេចក្តីសុខ សេចក្តីស្ងប់ និង សេចក្តីរីករាយស្រស់បស់ ជាឋានសួគ៌តាមផ្លូវចិត្ត ។ ព្រោះហេតុដូច្នោះ ដោយសារតែចិត្តនេះ បុគ្គលអាចធ្លាក់នរក ឡើងឋានសួគ៌ ជាសត្វនរក ជាសត្វតិរច្ឆានជាមនុស្ស ជាទេវតា ជាព្រហ្ម ជាព្រះអរិយបុគ្គលបាន ស្រេចតែលើការសន្សំនូវអំពើល្អឬអាក្រក់ តិចច្រើនប៉ុណ្ណោ ។

## ប្រភេទទី ២ ▲

## នរកដែលមើលឃើញដោយផ្ទាល់ភ្នែក

អ្នកដែលធ្លាប់ចូលទៅក្នុងគុក និង ទីឃុំឃាំងនានា ច្បាស់ជាបានឃើញនូវពពួកមនុស្សដែលធ្លាក់នរកទាំងរស់ជាមិនខាន ។ ពួកគេរងទុក្ខវេទនាក្នុងលក្ខណៈផ្សេងៗពីគ្នា អ្នកខ្លះក៏ជាប់ក្នុងរយៈពេលវែង អ្នកខ្លះក៏ជាប ក្នុងរយៈពេលខ្លី តាមតែទោសស្រាលធ្ងន់របស់គេដែលបានប្រព្រឹត្ត ។ ក្នុងសភាពដំណាលគ្នានោះយើងក៏បានឃើញអ្នកដែលប្រព្រឹត្តខ្លួនជាពលរដ្ឋល្អ ឧស្សាហ៍ព្យាយាមប្រកបមុខរបរចិញ្ចឹមជីវិតតាមសម្មា

អាជីវោ រស់នៅដោយសុខដុមរមនា មានសេចក្តីសុខ សេចក្តីថ្លៃថ្នូរ សម្បូរសប្បាយគ្រប់បែបយ៉ាង ។ មនុស្សទាំងនេះ បើប្រៀបធៀបទៅនឹងអ្នកទោសដែលរស់នៅក្នុងគុក យើងឃើញថាវាមានសភាពខុសគ្នាស្រលះ ជាឋានទរកឋានសួគ៌ដែលជាភស្តុតាងបង្ហាត់បង្ហាញអោយមនុស្សមើលឃើញផលនៃអំពើល្អ និងអំពើអាក្រក់ ថាវាខុសគ្នាយ៉ាងណានៅក្នុងបច្ចុប្បន្នទាន់ភ្នែកនេះ ។

## ប្រភេទទី ៣ ▲

### នរកពិតប្រាកដដែលមើលមិនឃើញដោយភ្នែក

*យើងប្រហែលជាធ្លាប់ឮធ្លាប់ស្តាប់មកហើយអំពីរឿងឋាននរក ថាមានសភាពប្លែកពន្លឹកខុសពីធម្មតា តែសរុបសេចក្តីមកមានតែម្យ៉ាងគឺ នរកកើតមានសំរាប់ដាក់ទោសមនុស្សអាក្រក់ ឋានសួគ៌មានសំរាប់ផ្តល់រង្វាន់ដល់មនុស្សល្អ ។ បញ្ហាសំខាន់គឺ នរកដូចដែលបានពោលមកនេះ តើមានមែនដែរឬទេ ប្រសិនបើមានចុះហេតុអ្វីបានជាមិនឃើញ?*

*ប្រសិនបើនិយាយត្រឹមតែរឿងឃើញ ឬ មិនឃើញនោះ ចាំបាច់ពោលថ្វីដល់ទៅរឿងឋាននរកឋានសួគ៌ដែលនៅក្នុងលោកមួយផ្សេងពីមនុស្ស សូម្បីតែទីក្រុង ឬ ប្រទេសដែលនៅឆ្ងាយៗ យើងក៏មើលមិនឃើញត្រូវអាស្រ័យស្តាប់ការពណ៌នារបស់អ្នកដទៃដូចគ្នា ។ រឿងនរកសួគ៌ពិតប្រាកដនោះ អ្នកមានគុណធម៌ខាងផ្លូវចិត្តខ្ពស់រហូតអាចឃើញបានដោយភ្នែកខាងក្នុងបានដំណាលប្រាប់ថាមានមែន ចំណែកពាក្យពណ៌នាលំអិតទៀតនោះជារឿងដែលនិយាយតៗគ្នាមក យើងមិនគួរចាប់អារម្មណ៍ច្រើនហួសហេតុពេក ទេ ។*

*ឥឡូវយើងនាំគ្នាពិចារណាមើលសិនថាមានឬមិនមាន ហើយក្នុងការវិនិច្ឆ័យរឿងនរកសួគ៌នេះ បើអាចអាស្រ័យវិជ្ជាវិទ្យាសាស្ត្រមកជួយអធិប្បាយបាន យើងក៏គួរតែសាកល្បងវិនិច្ឆ័យមើលផងដែរ ។*

យើងសាកល្បងពិនិត្យមើលខាងផ្នែកអ្នកមិនជឿជាមុនសិនថា មានហេតុផលយ៉ាងណា? ចំពោះសំនួរនេះ យើងតែងតែបានទទួលចំលើយថា ព្រោះមិនឃើញ មិនដឹង មិនប្រត្យក្ស ឬ យកមកជាតឹកតាងមិនបាន ។ ក្នុងការវិច្ឆ័យបញ្ហាណាមួយក៏ដោយ យើងសំអាងត្រឹមតែពាក្យថា មិនដឹង មិនឃើញមកជាហេតុផលថា របស់នោះ ឬ ហេតុការណ៍នោះមិនមានក៏មិនបាន ។ ការបំពានច្បាប់ ដោយអាងថាមិនដឹងច្បាប់ រមែងមិនធ្វើអោយ អំណះអំណាងនោះមានប្រសិទ្ធិភាពឡើយ ការដែលយើងមិនដឹងថាភ្លើងជារបស់ក្តៅហើយលូកដៃចូលទៅក្នុងភ្លើងនោះ ភ្លើងនឹងទទួលស្គាល់នូវអំណះអំណាងនោះហើយនឹងមិនធ្វើអោយដៃរបស់យើងក្តៅដែរឬ? ក្នុងការចោទឆ្លើយឬវិភាគបញ្ហា ណាមួយ យើងនឹងយកអំណះអំណាង ត្រឹមតែពាក្យថាមិនដឹងមិនឃើញជាហេតុផលក៏នឹងធ្វើអោយសំដីរបស់យើងគ្មានទឹកដម ព្រោះការវិនិច្ឆ័យបញ្ហាផ្សេងៗ យើង

ចាំបាច់ត្រូវអោយសេចក្តីវិនិច្ឆ័យនោះមានគ្រឹះនៅលើកាដឹង មិនមែនលើការមិនដឹងទេ ទោះជាមិនដឹងប្រចក្ស ក៏សុំអោយជាការដឹងដែលប្រកបដោយហេតុផល ក៏ជាការល្អ ។ ត្រង់សេចក្តីថា នាំយកមកបង្ហាញមិនបាននោះ បើនរកសួគ៌នៅដោយឡែកពីគ្នា គឺពីភពមនុស្សយើងនោះ ក៏ជាការត្រឹមត្រូវហើយដែលយើងមិនអាចយកមកបង្ហាញអោយគ្នាមើលបាន ។ ចាំបាច់ពោលថ្វីដល់ទៅរឿងយ៉ាងនោះ សូម្បីតែរឿងក្នុងលោកយើងនេះ ដូចជាមានអ្នកដំណាលពីរឿងភ្នំហិមាល័យអោយស្តាប់ យើងក៏មិនជឿថាមាន ព្រោះយើងមិនបានដឹង មិនបានឃើញ ហើយគេមិនអាចយកភ្នំនោះមកបង្ហាញអោយយើងឃើញបាន ។ ការមិនដឹងមិនឃើញ ឬការដែលមិនអាចលើកភ្នំហិមាល័យទៅបង្ហាញអោយគេឯងឃើញនោះ មិនមែនធ្វើអោយភ្នំនោះ ទៅជាគ្មានតាមការអះអាងរបស់អ្នកមិនជឿនោះទេ ។

ឋាននរកឋានសួគ៌ បើតាមការអធិប្បាយរបស់លោកអ្នកអប់រំចិត្តជាន់ខ្ពស់បានអោយដឹងថា មានការរស់នៅប្លែកពីមនុស្ស និងកន្លែងផ្សេងពីមនុស្ស ហើយមានលក្ខណៈជាអាថិកំបាំង អ្នកដែលមានសមត្ថភាពអាចដឹងអាចឃើញបានទាល់តែមានឧបករណ៍ពិសេសគឺទិព្វចក្ខុ (ភ្នែកទិព្វ) ហើយទិព្វចក្ខុនេះមិនមែនកើតឡើងឯងៗនោះទេ ទាល់តែអាស្រ័យការអប់រំហាត់ពត់លត់ដំចិត្តដល់កំរិត ទើបអាចដឹងអាចឃើញបាន ។

អ្នកវិទ្យាសាស្ត្រជាច្រើនបានព្យាយាមពិសោធន៍សមត្ថភាពក្នុងរឿងទិព្វចក្ខុ រឿងចេតោបរិយញ្ញាណ (ការកំណត់ដឹងចិត្តអ្នកដទៃ) ដោយវិធីខាងវិទ្យាសាស្ត្រ ។ បញ្ជាក់អោយឃើញថា បើយើងហាត់ពត់អប់រំល្អហើយ ក៏នឹងបង្កើតនូវសមត្ថភាពក្នុងការដឹងឃើញនូវអ្វីៗយ៉ាងចម្លែកអស្ចារ្យជាទីបំផុត ដែលមនុស្សធម្មតាមិនអាដឹងមិនអាចឃើញបាន ។ អ្នកវិទ្យាសាស្ត្រដែលខំស្រាវជ្រាវពីរឿងមាន់បានព្យាយាមស្រាវជ្រាវរកជម្ងឺមាន់មួយប្រភេទឈ្មោះថា Newcastle ដែលជាវីរុសមួយប្រភេទតូចរហូតដល់អាចលេចចេញពីតម្រងបាន វីរុសប្រភេទនេះត្រូវប្រើឧបករណ៍មីក្រូទស្សន៍ ដែលមានសមត្ថភាពខ្ពស់ទើបអាចឃើញបាន ព្រោះត្រូវពង្រីកអោយធំជាងមុនរហូតដល់ទៅរាប់ម៉ឺនរាប់សែនដង ។ ពេលនេះយើងមើលដោយភ្នែកទទេមិនឃើញ ហើយយើងមិនព្រមប្រើឧបករណ៍បែបវិទ្យាសាស្ត្រ យើងក៏គ្មានផ្លូវដទៃណាក្រៅពីជឿថាមិនមាន ឬបើជឿថាមានដូចអ្នកវិទ្យាសាស្ត្រនិយាយ ជំនឿនោះក៏គ្មានអ្វីវិសេសវិសាលជាង ជំនឿតាមគេថាក្នុងរឿងដទៃៗទៀត ដូចជារឿងនរកសួគ៌ដូច្នេះដែរ បើត្រូវការពិសោធន៍អោយឃើញការពិត យើងក៏ត្រូវបង្កើតឧបករណ៍គឺទិព្វចក្ខុដែលមានវិធីអាចអោយយើងបង្កើតបាន តែយើងច្រើនតែប្រើវិធីផ្លូវកាត់ គឺមិនព្រមបង្កើតឧបករណ៍ ហើយតាំងទាមទារអោយឃើញដែរ នេះជារឿងដែលមិនអាចជួយបាន ។

ពួកអ្នកតារាសាស្ត្រអាចជួយលាតបង្ហាញនូវបញ្ហានេះបានល្អ ល្អមយកជាការបាន ព្រោះបើពោលតាមហេតុផលខាងផ្នែកតារាសាស្ត្រថាភពដទៃដែលនៅផ្សេងក្រៅពីភពយើងនៅមានជាច្រើនលានច្រើនកោដិទៀត ។ ដូច្នេះ ត្រង់សេចក្តីដែលថា មានមនុស្សក្នុងភពដទៃទៀត ឬមានអ្នកមានសេចក្តីសុខជាងមនុស្សយើង គឺអាចមានសេចក្តីចំរើនប្រហែលនឹងទេវតាក្នុងឋានសួគ៌ឬក្នុងភពខ្លះទៀត នឹងមានមនុស្សឬសត្វរស់នៅដោយសេចក្តីទុក្ខវេទនាដូចធ្លាក់នរកនោះ គ្មានអ្វីចំលែកទេ ហើយការរស់នៅរបស់វត្ថុមានជីវិតទាំងនោះអាចមានលក្ខណៈអស្ចារ្យនិងអាថិកំបាំងជាងមនុស្សលោកយើងនេះប៉ុណ្ណាក៏បានដែរ ព្រោះតែ ក្នុងលោកយើងនេះក៏មានសត្វជាច្រើនរយលានប្រភេទ តាំងពីសត្វតូចបំផុតរហូតមើលមិនឃើញ និងសត្វធំៗ ដែលស៊ីអាហារខុសគ្នា អាស្រ័យនៅក្នុងទឹក ក្នុងដី ឬ ក្នុងដើមឈើ លើដើមឈើ លើផែនដី ខុសប្លែកគ្នាតាមប្រភេទ តាមក្រុម ។ ហេតុនេះ ឋានសួគ៌ឋាននរក ដែលមាននៅក្នុងលោកដទៃក៏អាចមានបានដែរ សូម្បីតាមផ្លូវវិទ្យាសាស្ត្រ ក៏អាចពិសោធន៍បានខ្លះៗ ។

ប៉ុន្តែ ឋានសួគ៌ឋាននរកដែលពិតប្រាកដជារឿងដែលមើលមិនឃើញដោយមង្សចក្ខុ (ភ្នែកធម្មតា) យើងអាចស្វែងយល់ពីរឿងឋានសួគ៌ឋាននរកនៅក្នុងចិត្តរបស់យើង ឬឋានសួគ៌ឋាននរកដែលឃើញនឹងភ្នែកបច្ចុប្បន្នក្នុងការរស់នៅរបស់មនុស្សអាក្រក់ មនុស្សល្អដែលមានភាពខុសប្លែកគ្នានោះវិញប្រសើរជាង ថាទោះជាយ៉ាងណា យើងក៏នៅតែអាចមើលឃើញឋានសួគ៌ នរកបាន ឬអាចដឹងបានដោយចិត្តរបស់ខ្លួន ។ កាលបើឃើញ ដឹង ដូច្នេះហើយ យើងនឹងខំវៀរចាកហេតុអាក្រក់ ធ្វើតែហេតុដែលល្អៗ ដើម្បីមិនអោយខ្លួនយើងធ្លាក់នរកទាំងរស់ ទោះជាយើងមិនជឿរឿងឋានសួគ៌នរកពិតប្រាកដក៏មិនធ្វើអោយប៉ះពាល់ដល់ព្រះធម៌ព្រះពុទ្ធសាសនាដែរ ព្រោះនៅមាននរកសួគ៌ ក្នុងបច្ចុប្បន្នអោយយើងឃើញបានទៀត ។ រឿងដែលសំខាន់គឺ សុំអោយយើង វៀរចាកអំពើអាក្រក់ ហើយប្រព្រឹត្តល្អ ប៉ុណ្ណឹងជាការប្រសើរយ៉ាងក្រៃលែង ។ ព្រះពុទ្ធសាសនាមិនមែនប្រៀនប្រដៅអោយមនុស្សគិត ប្រព្រឹត្តអំពើល្អត្រឹមតែទៅកាន់ឋានសួគ៌ ប៉ុណ្ណឹងទេ តែប្រៀនប្រដៅអោយបានទៅកាន់គោលដៅដែលខ្ពស់ជាងនោះទៀត គឺអោយបានចូលដល់ព្រះនិព្វានដែលខ្ពស់ជាងឋានសួគ៌ គឺគ្មានការប្រែប្រួលប្តូរផ្លាស់តទៅទៀតឡើយ ព្រោះឋានសួគ៌នៅមានភាពមិនស្ថិត ស្ថេរមិនទៀង អ្នកនៅក្នុងឋានសួគ៌ក៏មិនទាន់អស់កិលេស ទើបព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅរឿងនិព្វានដែលជារឿងនៃការរំលត់កិលេសនិងទុក្ខទាំងពួង ។